# អភិរក្សនិយម ( ការរក្សាអោយគង់វង់ ) LPS

**(LPS Conservatorship)**

## មាត្រាលេនធ័រម៉េន ផេទ្រីស ស្ស៊័ត Lanterman-Petris-Short (LPS)

**Welf. & Inst. Code Section 5350 et seq.**

### អ្វីទៅជាអភិរក្សនិយម LPS?

អភិរក្សនិយម LPS គឺជាភាពដែលចៅក្រម បានចាត់តាំងអោយបុគ្គលម្នាក់ ធ្វើការសំរេចទៅលើរូបអ្នក។ បុគ្គលនេះហៅថាអភិរក្សជន (អ្នកថែរក្សាអោយគង់វង់)។

### តើខ្ញុំមានសិទ្ធរស់នៅទីណា បើសិនជាខ្ញុំទទួលនូវភាពអភិរក្សនិយម LPS ?

- អភិរក្សជន LPS មានមុខនាទីចាត់តាំងរូបអ្នក ដាក់ បញ្ចូលទៅទីកន្លែងដែលសមស្របទៅតាមសេចក្ដីត្រូវការរបស់អ្នក។
- អភិរក្សជនត្រូវតែរក្សាការគាំទ្រ ដើម្បីអោយរូបអ្នករស់នៅនៅក្នុងទីកន្លែងរបស់អ្នក ឬគេហដ្ឋានរបស់មិត្តភ័ក្រ និងសមាជិកគ្រួសាររបស់អ្នក។
- អ្នកមានសិទ្ធរស់នៅជិតក្រុមគ្រួសារ មិត្តភ័ក្រ និងសហគមន៏របស់អ្នក។
- អ្នកមានសិទ្ធរស់នៅទីណាដែលអ្នកនឹងរៀនសូត្រជាបន្ថែមទៀតអំពីការប៉ិនប្រសប់ផ្នែករស់នៅដោយពុំមានការពឹងផ្អែក។

### តើនៅពេលណាដែលគេដាក់ខ្ញុំនៅក្នុងភាពអភិរក្សនិយម LPS?

អ្នកអាចឋិតនៅក្នុងភាពអភិរក្សនិយម LPS បើសិនជាចៅក្រមសំរេចថាអ្នកជា "អសមត្ថភាពដ៏ធ្ងន់ធ្ងរ "។ បានន័យថាអ្នកមានការខ្វះសមត្ថភាពផ្នែកសតិអារម្មណ៍ ដែលធ្វើអោយអ្នកពុំអាចផ្ដល់ម្ហូបអាហារ សំល្យេកបំពាក់ និងទីលំនៅដល់ខ្លួនរបស់អ្នក។

### តើអ្វីទៅជាអសមត្ថភាពផ្នែកសតិអារម្មណ៍?

មាត្រា LPS គឺសំដៅទៅលើ "ខួរក្បាលមានដំណើរការពុំដូចធម្មតា(ពុទ្ធិវិបល្លាស)"។ ដែលបានបកស្រាយយ៉ាងទូលំទូលាយ ចំពោះអ្នកដែលបានទទួលការវិនិច្ឆ័យរោគ ដូចជារោគខូចខួរក្បាល របួសខួរក្បាល ឬស្ថានភាពផ្សេងៗ នៃសេរីរាង្គ។ ដោយពុំមានរួមតែការវិនិច្ឆ័យរោគពន្យឺតសតិអារម្មណ៍ (វិកលប្រាជ្ញា)តែមួយបែបនោះទេ។

### តើចៅក្រមធ្វើការសំរេចយ៉ាងណា បើសិនជាខ្ញុំត្រូវការអភិរក្សជន?

- ចៅក្រមពិនិត្យឡើងវិញទៅលើការប្ដឹងសុំ ដែលអាចធ្វើឡើងបានដោយភ្នាក់ងារស៊ើបអង្កេតផ្នែកអភិរក្សនិយមប្រចាំស្រុក។
- ត្រូវមានអ្នកចិត្តវិជ្ជាចំនួនពីរនាក់ ដែលធ្វើការគាំទ្រ។
- អ្នកត្រូវទទួលនូវក្រដាសចម្លងនៃការប្ដឹងសុំ ហើយបានទទួលដំណឹងថា ពេលណាដែលចៅក្រមនឹងបើកសវនាការទៅលើកិច្ចការនេះ។

### តើសិទ្ធិរបស់ខ្ញុំមានអ្វីខ្លះក្នុងការប្រឆាំងតបវិញ?

- អ្នកមានសិទ្ធជួលមេធាវី ឬទទួលអ្នកតំណាងផ្នែកចុងចោទសាធារណ: ដោយឥតគិតថ្លៃ។
- អ្នកមានសិទ្ធទទួលការជំរះទោសដោយគណ:វិនិច្ឆ័យ។
- ផ្នែកស្រុកត្រូវតែបង្ហាញនូវសេចក្ដីត្រូវការដោយមាន "ភ័ស្តុតាងហួសពីភាពមន្ទិលសង្ស័យសមហេតុសមផល"។
- អ្នកមានសិទ្ធចូលរួមនៅក្នុងសវនាការ ហើយធ្វើជាកសិណសាក្សី ឬអោយក្រុមគ្រួសារ ឬមិត្តភ័ក្រធ្វើជាកសិណសាក្សីដល់រូបអ្នក។

- អ្នកមានសិទ្ធធ្វើជីការកោះហៅយកឯកសារ និង ធ្វើជាសាក្សី និងដើម្បីទទួល ពត៌មានតាមរយ:ការរកឃើញ។
- អ្នកមានសិទ្ធស្នើសុំការប្រមាណមើលផ្នែកសតិអារម្មណ៍ដោយឯករាជ្យ ទៅលើសេចក្តីត្រូវការនៃភាពអភិរក្សនិយម។

## តើខ្ញុំត្រូវប្រុងប្រៀបខ្លួនដោយរបៀបណាសំរាប់ឡើងតុលាការ?

- សំអិតសំអាងខ្លួន ហើយស្លៀកសំលៀកបំពាក់អោយស្អាត ស្អំទៅតាមលទ្ធភាព។
- រក្សាសភាពស្ងប់ស្ងាត់ ទោះបីជាអ្នកពុំយល់ស្របជាមួយនឹងអ្វីដែលគេនិយាយអំពីរូបអ្នកក៏ដោយ។
- ទទួលស្គាល់ ពាក្យដែលវេជ្ជបណ្ឌិតថ្លែងថា អ្នកមានស្ថានភាពសតិអារម្មណ៍។
- បើសិនជាអ្នកពុំយល់ស្របជាមួយនិងការវិនិច្ឆ័យរោគរបស់វេជ្ជបណ្ឌិតទេនោះ សូមពន្យល់នូវហេតុផល។
- ទទួលស្គាល់ថា វេជ្ជបណ្ឌិតយល់ព្រមផ្តល់ថ្នាំពេទ្យ។
- បើសិនជាអ្នកពុំយល់ស្រប សូមពន្យល់នូវហេតុផល។
- រៀបចំគំរោងការសំរាប់ខ្លួន ដើម្បីបង្ហាញថា អ្នកអាចផ្តល់ម្ហូបអាហារ សំលៀកបំពាក់ និងទីលំនៅដល់ខ្លួនរបស់អ្នក។
- មានសេចក្តីថ្លែងជាលាយល័ក្ខអក្សរ ឬកសិណ៏សាក្សីអំពីជំនួយពីក្រុមទីបី បើសិនជាត្រូវការ។

## តើអ្វីទៅជំនួយក្រុមទីបី?

ជំនួយក្រុមទីបី គឺជាជំនួយពីសមាជិកគ្រួសារ មិត្តភ័ក្រ ឬអង្គការសហគមន៏ ដែលធ្វើការបញ្ជាក់ថា រូបអ្នកមានម្ហូបអាហារ សំលៀកបំពាក់ និងទីសំណាក់។ ឧទាហរណ៏មានរួមទៅដោយ :

- ម្តាយរបស់អ្នកជួយអ្នកចាត់ចែងប្រាក់ អេសអេសអាយ SSI។
- មិត្តសម្លាញ់របស់អ្នក នឹងមកមើលអ្នកជារៀងរាល់ថ្ងៃ ឬរស់នៅជាមួយអ្នក។
- បុគ្គលិកផ្នែកសង្គមកិច្ច (វើគហ្គ័រ) នឹងជួយអ្នករក និងថែទាំផ្ទះសម្បែង។
- គិលានុបដ្ឋាកម្នាក់ នឹងមកជួបអ្នកនៅបន្ទប់ជួល(អាផាតាមិន) របស់អ្នក ដើម្បីតាមពិនិត្យថ្នាំពេទ្យ និងសុខភាពកាយវប្បកម្មរបស់អ្នក។
- បុគ្គលិកជំនួយតាមផ្ទះ នឹងរៀបចំអាហារ។
- អ្នកឯកទេសផ្នែកហាត់ហ្វឹកហ្វឺនសតិអារម្មណ៍ នឹងជួយអ្នកក្នុងការរៀន ពីរបៀបរៀបចំអាហាររបស់អ្នក ជារៀងរាល់ថ្ងៃ។

## តើអ្នកណាជាអភិរក្សជនរបស់ខ្ញុំ?

- អ្នកអាចចាត់តាំងអោយជនណាម្នាក់ ធ្វើជាអភិរក្សជនរបស់រូបអ្នកទៅតាមចំណង់របស់អ្នក។
- ច្បាប់មានចែងនូវបញ្ជីចំណូលចិត្ត ដោយចាប់ផ្តើមឡើងដោយរាប់ពីសមាជិកគ្រួសារ។
- តុលាការធ្វើការសំរេចទៅលើការចាត់តាំង។
- អ្នកអាណាព្យាបាលប្រចាំស្រុកអាចទទួលការចាត់តាំងឡើង បើសិនជាពុំមានបុគ្គលណាម្នាក់នោះទេ។

## តើអភិរក្សនិយម LPS មានកំរិតរយ:ពេលចំនួនប៉ុន្មាន?

អភិរក្សនិយម LPS

អាចមានកំរិតពេលយ៉ាងច្រើនបំផុតចំនួន១ឆ្នាំ។

អាចស្នើសុំជាថ្មីឡើងវិញទៅផ្នែកតុលាការ នៅចុងឆ្នាំ។

## តើអ្វីទៅជាភាពអភិរក្សនិយម LPS បណ្តោះអាសន្ន?

LPS បណ្តោះអាសន្នគឺ នៅគ្រាដែលចៅក្រមចាត់តាំងអោយបុគ្គលម្នាក់ធ្វើការសំរេចជំនួសរូបអ្នកចំនួន៣០ថ្ងៃ។ មានតែភ្នាក់ងារស៊ើបអង្កេតប្រចាំស្រុកទេដែលអាចធ្វើការប្តឹងសុំ។ តាមធម្មតាកិច្ចការនេះអាចធ្វើឡើងដើម្បីទុករូបអ្នកនៅក្នុងមន្ទីរពេទ្យ នៅក្នុងកំឡុងពេលនោះ។ តែអ្នកមានសិទ្ធទទួលការចាត់ដាក់ទៅទីកន្លែង ដែលពុំមានការតឹងតែង។ អ្នកក៏មានសិទ្ធទទួលដំណឹងជាលាយល័ក្ខអក្សរយ៉ាងហោចណាស់ចំនួនប្រាំ(៥)ថ្ងៃ មុនពេលភាពអភិរក្សនិយមធ្វើឡើង។ អ្នកអាចស្នើសុំសវនាការដើម្បីប្រឆាំងតបវិញ។

## តើសិទ្ធអ្វីខ្លះដែលខ្ញុំរក្សាទុក បើសិនជាខ្ញុំឋិតនៅក្នុងភាពអភិរក្សនិយម LPS?

- អ្នកមានសិទ្ធទទួលកិច្ចបំរើ និងការឧបត្ថម្ភ ដើម្បីជៀសវាងពីភាពអភិរក្សនិយម។
- អ្នកមានសិទ្ធស្នៀកសំលៀកបំពាក់ដោយខ្លួនឯង និយាយទូរស័ព្ទដោយគ្មាននរណាលួចស្តាប់ ទទួលសំបុត្រលិខិត ដោយពុំមានការបើក ឬរបើក មានភ្ញៀវ មានទីកន្លែងទុកដាក់របស់របរដោយឡែក និងទុកប្រាក់កាក់របស់អ្នកដែលកំរិតចំនួនសមហេតុសមផល និងសិទ្ធិផ្សេងៗ ទៀត។
- អ្នកមានសិទ្ធចូលរួមនៅក្នុងការព្យាបាល និងការសំរេចចាត់តាំងដាក់ទៅទីកន្លែង។
- អ្នកមានសិទ្ធដ៏សំខាន់ ក្នុងការសំរេចដោយខ្លួនឯងទៅលើរាងកាយរបស់អ្នក។
- ដើម្បីគោរពទៅតាមការទទួលស្គាល់ទៅលើសិទ្ធិសំរេចដោយផ្ទាល់ខ្លួន សេចក្តីយល់ព្រមទទួលពត៌មានត្រូវតែធ្វើឡើងចំពោះការព្យាបាលផ្សេងៗ ដែលពុំមែនជាការទៀងទាត់។
- អ្នកទទួលនូវការសន្មតថា អ្នកមានសមត្ថភាពគ្រប់គ្រាន ក្នុងការទទួលការផ្តល់សេចក្តីយល់ព្រមទទួលពត៌មាន។ សម្ភារៈទំនាក់ទំនងបែបផ្សេងៗ អាចផ្តល់ឡើង ដើម្បីជួយដល់រូបអ្នក។
- អ្នកអាចធ្វើការសំរេច លើកលែងតែគេរកឃើញថា អ្នកពុំមានសមត្ថភាពទេនោះ។

## តើនណាជាអ្នកសំរេចថា តើខ្ញុំមានសមត្ថភាព ធ្វើការសំរេចទៅលើការព្យាបាល?

ចៅក្រមធ្វើការសំរេចទៅលើសិទអ្វីខ្លះ ដែលត្រូវដកហូតចេញពីរូបអ្នក។ ការសំរេចនេះឋិតនៅលើសេចក្តីរាយការណ៍ដោយអ្នកស៊ើបអង្កេតភាពអភិរក្សនិយមប្រចាំស្រុក។ សេចក្តីរាយការណ៍ អាចផ្តល់យោបល់ថា សិទ្ធិដូចខាងក្រោមនេះអាចត្រូវដកហូត ចេញពីរូបអ្នក :

- សិទ្ធបោះឆ្នោត
- សិទ្ធចុះកិច្ចសន្យា
- សិទ្ធបើកបរ
- សិទ្ធទុកកាំភ្លើងបាញ់
- សិទ្ធធ្វើការសំរេចទៅលើការព្យាបាលអំពីស្ថានភាពសតិអារម្មណ៍ និង
- សិទ្ធធ្វើការសំរេចទៅលើការព្យាបាលផ្សេងៗ។

## តើចៅក្រមធ្វើការសំរេចថា សិទ្ធិណាខ្លះដែលបដិសេធពុំផ្តល់អោយខ្ញុំ?

ចៅក្រមធ្វើការសំរេចទៅលើសិទ្ធិអ្វីខ្លះ ដែលត្រូវដកហូតចេញពីអ្នក គឺឋិតទៅលើកត្តាដែលផ្តល់ឡើងអំពីសមត្ថភាពរបស់អ្នកក្នុងការប្រើប្រាស់សិទ្ធណាមួយពិតប្រាកដ។ ឧទារហណ៍ដូចជា :

- អ្នកត្រូវរក្សាសិទ្ធិបោះឆ្នោត បើសិនជាអ្នកយល់ពីការចុះឈ្មោះបោះឆ្នោត។
- អ្នកត្រូវរក្សាសិទ្ធិធ្វើការសំរេចទៅលើការព្យាបាល បើសិនជាអ្នកយល់អំពីគុណសម្បត្តិ និងផលវិបត្ត នៃការព្យាបាល ដូចបានផ្តល់យោបល់ឡើង ហើយអាចបញ្ចេញនូវចំណូលចិត្ត ទៅលើជំរើសដែលត្រឹមត្រូវ។

## តើអភិរក្សជនធ្វើអ្វីខ្លះ?

អភិរក្សជនមានភារៈកិច្ច រកទីកន្លែងអោយអ្នករស់នៅ ដែលឋិតនៅទីដែលប្រកបទៅដោយ ពុំមានការប្រកាន់ខ្ជាប់ខ្លួន។

- អភិរក្សជនមានភារៈកិច្ចជួយ យកម្ហូបអាហារ សំលៀកបំពាក់ សេវាសុខភាព នឹងទីលំនៅ។
- អភិរក្សជនមានភារៈកិច្ចជួយអ្នកទទួលនូវសេវាផ្សេងៗ ដើម្បីបង្កើនសមត្ថភាពរស់នៅរបស់អ្នកដោយពុំមានការពឹងផ្អែក។
- តុលាការអាចផ្តល់អំណាចដល់អភិរក្សជនអោយធ្វើការចាត់ចែង និងរៀបចំកម្មសិទ្ធផ្សេងៗនេះជាកិច្ច ដែលហៅថា "អភិរក្សជនទ្រព្យសម្បត្តិ" [សូមអានសៀវភៅស្តើងស្តីពីសពុលកម្មអភិរក្សនិយម PAI]។
- លិខិតនៃភាពអភិរក្សនិយម បញ្ជាក់ច្បាស់លាស់នូវអភិរក្សជនរបស់អ្នក ហើយនិងសិទ្ធិត្រឹមត្រូវតាមច្បាប់ ដែលបានដលហូតចេញពីរូបអ្នក។

## តើខ្ញុំមានសិទ្ធអ្វីខ្លះ បើសិនជាតុលាការសំរេចថា ខ្ញុំពុំមានសមត្ថភាពធ្វើការសំរេចទៅលើការព្យាបាលនោះ?

អភិរក្សជនមានភារៈកិច្ចធ្វើការសំរេច ដោយយោងទៅតាមបំណងរបស់អ្នក។ បានសេចក្តីថា អ្នកមានសិទ្ធចូលរួមនៅក្នុងការសំរេចទៅលើការព្យាបាលទាំងអស់។ អភិរក្សជនត្រូវយល់ព្រមទៅតាមចំណង់របស់អ្នក លើកលែងតែការដែលអ្នកជ្រើសរើសនោះ ពុំត្រឹមត្រូវទៅតាមការព្យាបាល។

## តើខ្ញុំអាចធ្វើយ៉ាងណាបើសិនជាខ្ញុំពុំយល់ស្រប ជាមួយនឹងអភិរក្សជនរបស់ខ្ញុំ?

អ្នកអាចស្នើសុំអោយមានសវនាការតុលាការ បើសិនជាអ្នកមានអារម្មណ៍ថាអភិរក្សជនរបស់អ្នកមានអំណាចលើសលប់ទៅលើជីវិតរបស់អ្នក ឬបានចាត់ដាក់រូបអ្នកនៅទីកន្លែងដែលមានការតឹងតែងហួសហេតុនោះ។

- អ្នកអាចស្នើសុំ "សវនាការសារជាថ្មី" ទៅលើសិទ្ធិដែលបានដកហូតចេញពីរូបអ្នក ហើយប្រគល់អោយទៅអភិរក្សជនរបស់អ្នក។
- អ្នកអាចស្នើសុំ "សវនាការសារជាថ្មីទៅលើការចាត់ដាក់" ដើម្បីប្តូរទៅទីកន្លែងដែលពុំសូវតឹងតែង ជាទីដែលមានការលាយលំគ្នា។
- សវនាការសារជាថ្មី អាចស្នើសុំឡើងនៅក្នុងពេលណាក៏បាន ក្រោយពីការចាត់តាំងអភិរក្សជនបានធ្វើឡើង។
- នៅពេលដែលអ្នកស្នើសុំសវនាការ អ្នកអាចស្នើសុំសវនាការមួយទៀត ទៅលើបញ្ហាដដែល សំរាប់កំណត់ពេលប្រាំមួយ (៦)ខែ។
- អ្នកអាចប្រឆាំងតវ៉ា នឹងការចាត់ដាក់ ឬស្ថានភាពរបសអ្នកទៅលើការឃុំឃាំង ដោយដាក់ពាក្យសុំតាមបែបលិខិតដែលតុលាការបង្គាប់ឡើង។ "លិខិតតុលាការបង្គាប់" មានន័យថាបុគ្គលម្នាក់ធ្វើការឃុំឃាំងរូបអ្នក ហើយអ្នកមានសិទ្ធទទួលដឹងថា មកពីហេតុអ្វី។

## តើខ្ញុំអាចបំបាត់ភាពអភិរក្សនិយមដោយវិធីណា?

- អ្នកអាចស្នើសុំ "សវនាការសារជាថ្មី" ទៅលើស្ថានភាពរបស់អ្នក ក្នុងនាមជាអ្នកទទួលភាពអភិរក្សនិយម នៅក្នុងពេលណាក៏បាន បន្ទាប់ពីចៅក្រមបានធ្វើការចាត់តាំងអភិរក្សជនរួចនោះ។
- នៅពេលដែលអ្នកធ្វើការស្នើសុំ "សវនាការសារជាថ្មី" ទៅលើស្ថានភាពរបស់អ្នក ជាអ្នកទទួលភាពអភិរក្សនិយម អ្នកត្រូវតែរង់ចាំចំនួនប្រាំមួយ(៦)ខែ ដើម្បីស្នើសុំសវនាការបែបនេះទៀត។
- ភាពអភិរក្សនិយមរបស់អ្នក នឹងបញ្ចប់បន្ទាប់ពីកំណត់មួយឆ្នាំដោយស្វ័យប្រវត្តិ លើកលែងតែក្រសួងប្រចាំស្រុកធ្វើការបើកសុំណុំរឿងនេះឡើងវិញ។

## តើខ្ញុំអាចប្រឆាំងតវ៉ា ទៅលើការបើកសុំណុំរឿងឡើងវិញនៃភាពអភិរក្សនិយមដោយវិធីណា?

- ក្រសួងប្រចាំស្រុកត្រូវតែផ្តល់ពត៌មាន យ៉ាងហោចណាស់កំរិតចំនួនសាមសិបថ្ងៃ (៣០) មុនពលកំរិតមួយឆ្នាំនៃភាពអភិរក្សនិយមទទួលការបញ្ចប់ បើសិនជាគេមានបំណងធ្វើការស្នើសុំបើកសុំណុំរឿងសារជាថ្មីនោះ។
- ពុំដូច្នោះទេ សិទ្ធរបស់អ្នកក្នុងការប្រឆាំងតវ៉ាស្នើសុំបើកសុំណុំរឿងឡើងវិញ នឹងមានភាពដូចគ្នានិងសិទ្ធចាត់ដាក់ទៅក្នុងភាពអភិរក្សនិយមដូចនៅគ្រាដំបូង ដែលបានរៀបរាប់ឡើងនៅខាងលើនេះ។

---

បើសិនជាអ្នកមានសំណួរអំពីភាពអភិរក្សនិយម **LPS** សូមធ្វើការទាក់ទងនឹងផ្នែកគាំទ្រសិទ្ធរបស់អ្នកជម្ងឺប្រចាំស្រុក
អ្នកតំណាងផ្នែកចុងចោទសាធារណ:

ឬ

**Protection & Advocacy, Inc.**

លេខទូរស័ព្ទដោយឥតគិតថ្លៃ : 1-800-776-5746

Publication #5225.09
Cambodian
August 2001

---



Note: When this publication was originally published, we were known as Protection & Advocacy, Inc. (PAI). In October 2008, we changed our name from PAI to Disability Rights California.